ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ : ១០៦១ សរ.ជ.រ ប.ស្ថ

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង

ក្រសួងបរិស្ថាន បានពិនិត្យឃើញថា មានរោងចក្រមួយចំនួន ជាពិសេសរោងចក្រវាយនភ័ណ្ឌ និងជ្រលក់ពណ៌ រោងចក្របោកគក់ ឬបោះពុម្ព និងរោងចក្រកែច្នៃផលិតផលកសិ-ឧស្សាហកម្ម បានបញ្ចេញសំណល់រាវរបស់ខ្លួនដោយមិនបានធ្វើប្រព្រឹត្តិកម្មសម្អាត ឬ អាងប្រព្រឹត្តិកម្មខ្លះមិនបានដំណើរការឱ្យជាប់លាប់ និងអាងប្រព្រឹត្តកម្មខ្លះទៀតមិនមានសមត្ថភាពឆ្លើយតបតាមទៅនឹងបរិមាណសំណល់រាវដែលបានបង្កើត និងបញ្ចេញ ។ល។ ដែលជាហេតុបង្កឱ្យមានការពុលដោយផ្ទាល់ ឬដោយប្រយោលទៅដល់គុណភាពទឹក ដី និងបង្កផលប៉ះពាល់ទៅដល់សុខភាពរបស់ប្រជាពលរដ្ឋដែលរស់នៅជុំវិញប្រភពបំពុល។ ដោយពិនិត្យឃើញពីស្ថានភាពដ៏មានគ្រោះថ្នាក់ដែលបណ្តាលមកពីសកម្មភាពល្មើសខាងលើ ក្រសួងបរិស្ថាន សូមដាក់ចេញនូវវិធានការចំពោះមុខមួយចំនួនដូចខាងក្រោម៖

១.ចំពោះរោងចក្រ សហគ្រាស និងសិប្បកម្ម ដែលពុំទាន់មានអាងប្រព្រឹត្តិកម្មសម្អាតសំណល់រាវ ត្រូវតែប្រញាប់រៀបចំអាងប្រព្រឹត្តិកម្មសម្អាតសំណល់រាវឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសមុន និងបង្ហូរចូលទៅក្នុងប្រព័ន្ធលូសាធារណៈ ឬប្រភពទឹកសាធារណៈដ៏ទៃទៀត។

២.ចំពោះរោងចក្រ សហគ្រាស និងសិប្បកម្ម ដែលមានអាងប្រព្រឹត្តិកម្មសម្អាតសំណល់រាវ ប៉ុន្តែអាងប្រព្រឹត្តិកម្មសម្អាតនោះមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ឬពុំអាចមានលទ្ធភាពធ្វើការសម្អាតសំណល់រាវឱ្យឆ្លើយតបតាមកម្រិតកំណត់ស្តង់ដារ ត្រូវតែធ្វើការកែតម្រូវអាងប្រព្រឹត្តិកម្មសម្អាតសំណល់រាវជាបន្ទាន់ ដោយធ្វើយ៉ាងណាដើម្បីធានាឱ្យការបញ្ចេញសំណល់រាវរបស់ខ្លួនមិនបង្កផលប៉ះពាល់ដល់បរិស្ថាន និងសុខភាពប្រជាពលរដ្ឋ។

៣.ចំពោះរោងចក្រ សហគ្រាស និងសិប្បកម្ម ដែលមានអាងប្រព្រឹត្តិកម្មសម្អាតត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសរួច ត្រូវតែដាក់ឱ្យដំណើរការជាប់ជាប្រចាំ ហើយសំណល់រាវដែលបានធ្វើប្រព្រឹត្តិកម្មសម្អាតរួចត្រូវតែឆ្លើយតបតាមកម្រិតកំណត់ស្តង់ដារនៃការបញ្ចេញ។

៤.សំណល់រាវដែលបានធ្វើប្រព្រឹត្តិកម្មសម្អាតរួច ត្រូវបង្ហូរតាមបណ្តាញលូដាច់ដោយឡែក និងនៅត្រង់ចំណុចបញ្ចេញនៅខាងក្រៅបរិវេណរោងចក្រមុនតភ្ជាប់ទៅប្រព័ន្ធលូសាធារណៈ ឬបញ្ចេញទៅក្នុងប្រភពទឹក ប្រភពទឹកសាធារណៈ នៅត្រង់ចំណុចបញ្ចេញនេះត្រូវរៀបចំអណ្តូងលូ ដែលមានគម្របអាចបិទបើក

បានងាយស្រួល ដើម្បីឱ្យភ្នាក់ងារមានសមត្ថកិច្ចចុះធ្វើការត្រួតពិនិត្យនិងងាយយកសំណាកទឹកសម្រាប់ធ្វើការវិភាគ។

៥.ការបញ្ចេញសំណល់រាវក្រោយប្រព្រឹត្តិកម្មសម្អាតរួច ចូលទៅក្នុងប្រព័ន្ធលូ ឬប្រភពទឹកសាធារណៈ ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថានជាមុន និង

៦.ម្ចាស់ ឬអ្នកទទួលខុសត្រូវប្រភពបំពុលទាំងឡាយណា ដែលខកខានមិនបានអនុវត្តតាមបណ្តាវិធានការដូចមានចែងក្នុងសេចក្តីជូនដំណឹងនេះ ឬ/និងលិខិតបញ្ជាកែប្រែជាលាយលក្ខណ៍អក្សររបស់ក្រសួងបរិស្ថាន ម្ចាស់ ឬអ្នកទទួលខុសត្រូវប្រភពបំពុលទាំងនោះ នឹងត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ឬ/និង ត្រូវប្រឈមចំពោះមុខច្បាប់ជាធរមាន ដោយអនុលោមតាមទំហំនៃបទល្មើសដែលខ្លួនបានប្រព្រឹត្តជាក់ស្តែង។

ទទួលបាននូវសេចក្តីជូនដំណឹងនេះ ក្រសួងបរិស្ថានសង្ឃឹមនិងជឿជាក់យ៉ាងមុតមាំថា ម្ចាស់ ឬអ្នកទទួលខុសត្រូវរោងចក្រ សហគ្រាស និងសិប្បកម្មទាំងអស់ដែលពាក់ព័ន្ធនឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត៕

ព័ត៌មានបន្ថែមទំនាក់ទំនងលេខទូរស័ព្ទ៖

- ០៩២ ៩៩៦ ៩០៣
- ០១២ ៨៦៣ ៧៦៣
- ០១២ ៧២០ ៣៧៥
- ០៧៨ ៥៦៧ ៥៦៧